ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ : ១០៥១ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**គោរពជូន**

**សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**កម្មវត្ថុ:** ករណីសំណើសុំគោលការណ៍ពន្លឿនការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**យោង:** - លិខិតលេខ ០៦៣ ល.ស/គ.ជ.អ.ប ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

- ចំណាររបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៦ ។

សេចក្ដីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមគោរពជម្រាបជូនសម្ដេចក្រឡាហោម មេត្តាជ្រាបថា ចំពោះសំណើរបស់ក្រសួងមហាផ្ទៃដែលបានគោរពស្នើសុំគោលការណ៍ពន្លឿនការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះ រាជរដ្ឋាភិបាលបានសម្រេចដូចខាងក្រោម ៖

**ទីមួយ** ៖ អនុញ្ញាតឲ្យ គ.ជ.អ.ប ដឹកនាំរៀបចំសេចក្ដីព្រាងបញ្ជីមុខងារនានាដែលត្រូវផ្ទេរពីក្រសួង ស្ថាប័នទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមកិច្ចដំណើរការដូចបានជម្រាបជូនក្នុងលិខិតចុះក្នុងយោងខាងលើ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។ បន្ទាប់ពីមានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ត្រូវផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមបញ្ជីមុខងារដែលបានឯកភាពពីរាជរដ្ឋាភិបាល ដោយត្រូវផ្ទេរភ្ជាប់ទៅជាមួយនូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសម្រាប់ការអនុវត្តមុខងារទាំងនោះ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ត្រូវរៀបចំយន្តការ និងនីតិវិធីចាំបាច់នានាដើម្បីធានាដល់ការផ្ទេរធនធានហិរញ្ញវត្ថុ និងធនធានមនុស្សស្របជាមួយនឹងការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យបានទាន់ពេលវេលា ។

**ទីពីរ** ៖ អនុញ្ញាតឲ្យ គ.ជ.អ.ប ដឹកនាំ សម្របសម្រួលរៀបចំសិក្សាអំពីស្ថានភាពនៃការគ្រប់គ្រង និងការអនុវត្តការងាររបស់ការិយាល័យជំនាញរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យលទ្ធភាព និងផ្ដល់ជម្រើសនានាសម្រាប់រៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ដោយធ្វើសមាហរណកម្មការិយាល័យជំនាញទាំងនោះទៅក្នុងរចនា-

សម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅតាមក្រុង ស្រុក ខណ្ឌ។ បន្ទាប់ពីការសិក្សាកំណត់ជម្រើសនានាសម្រាប់រៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌរួចហើយ ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ស៊ូ គិរិន្ទ**

**ចម្លងជូន:**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានី ខេត្ត
-ឯកសារ-កាលប្បវត្តិ